គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតនៅឃុំស្វាយចចិប ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ

ដោយមានការគាំទ្រពី គណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង **សមាគមអាដហុក** បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយស្តីពី **ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅ**ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ** កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ **៨២**នាក់ (**៦៥%**ជាស្ត្រី) ពីគ្រប់ភូមិក្នុងឃុំ ដែលរួមមាន តំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ សមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្នយកចិត្តទុកដាក់ដោះស្រាយ និង/ឬ គណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

### តម្រូវការជាអាទិភាពទាំង៥ ក្នុងឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

**១. ការសាងសង់ផ្លូវ**

- សុំផ្លូវក្រាលគ្រួសក្រហម**ចំនួន៦**ខ្សែ ដោយ**ខ្សែទី១** មានប្រវែង៥០០ម៉ែត្រ ទទឹង៥ម៉ែត្រ ពីភូមិអណ្តូងល្វា ដល់ភូមិត្រពាំងខ្ទុំ។ **ខ្សែទី២** មានប្រវែង១៥០០ម៉ែត្រ ទទឹង៥ម៉ែត្រ ពីភូមិចចិបពីផ្លូវធំខាងជើង ទៅខាងត្បូងទល់ភូមិជ្រៃ។ **ខ្សែទី៣**មានប្រវែង៤០០ម៉ែត្រ ទទឹង៥ម៉ែត្រ នៅក្នុងភូមិចេក។ **ខ្សែទី៤**មានប្រវែង១២០០ម៉ែត្រ ទទឹង៣ម៉ែត្រនៅក្នុងភូមិចារ្យ។ **ខ្សែទី៥**ប្រវែង១០០០ម៉ែត្រ ទទឹង៥ម៉ែត្រ នៅក្នុងភូមិពង្រ។ **ខ្សែទី៦**មានប្រវែង១៣៥០ម៉ែត្រ ទទឹង៥ម៉ែត្រ ពីភូមិចចិប ដល់ភូមិជ្រៃ។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងឲ្យហើយនៅឆ្នាំ២០១៣។
- សុំផ្លូវ១ខ្សែក្នុងភូមិត្រពាំងធ្លក មានប្រវែង៦០០ម៉ែត្រ និងទទឹង៤ម៉ែត្រ។ សូមចាប់ផ្តើមធ្វើពីឆ្នាំ២០១២ និងបញ្ចប់ដើមឆ្នាំ២០១៤ ។

**២. ការស្នើសុំវគ្គបណ្តុះបណ្តាល**

- សុំបើកវគ្គបណ្តុះបណ្តាលពីរបៀបធ្វើជីអ៊ីអឹម ចំនួន១០វគ្គ ឲ្យបានទូទាំងឃុំស្វាយចចិប។ សូមចាប់ផ្តើមពីដើម ឆ្នាំ២០១២ ដល់ចុងឆ្នាំ២០១៤។

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

- សុំបើកវគ្គបណ្តុះបណ្តាលពីរបៀបចិញ្ចឹមសត្វចំនួន១០វគ្គ ក្នុងឃុំស្វាយចចិបទាំងមូល។ សូមចាប់ផ្តើមពីឆ្នាំ ២០១២ ដល់ចុងឆ្នាំ២០១៣។
- សុំបើកវគ្គផ្សព្វផ្សាយអំពីច្បាប់អំពើហិង្សាក្នុងគ្រួសារ និងច្បាប់ភូមិបាល ឲ្យបានចំនួន៨វគ្គ ទូទាំងឃុំស្វាយចចិប។ សូមចាប់ផ្តើមពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៣។

**៣. ការស្នើសុំស្រះទឹក អណ្តូង លូ ការស្តារស្រះ និងប្រឡាយ**

- សុំ**ស្រះទឹក**១កន្លែង មានប្រវែង១០០ម៉ែត្រ ទទឹង៥០ម៉ែត្រ ជម្រៅ៥ម៉ែត្រ នៅក្នុងភូមិស្តុក។ សូមចាប់ផ្តើមពីឆ្នាំដើមឆ្នាំ២០១២ និងបញ្ចប់ចុងឆ្នាំ២០១៤។
- សុំ**ស្តារស្រះទឹក**១កន្លែង ដែលមានបណ្តោយប្រវែង១០០ម៉ែត្រ ទទឹង៥០ម៉ែត្រ និងជម្រៅ៥ម៉ែត្រ នៅក្នុងភូមិត្រយឹងទេ។ សូមចាប់ពីដើមឆ្នាំ២០១២ និងបញ្ចប់ចុងឆ្នាំ២០១៣។
- សុំ**អណ្តូងទឹក**ចំនួន១៥អណ្តូង សម្រាប់ទូទាំងឃុំស្វាយចចិប។ សូមចាប់ផ្តើមពីឆ្នាំ២០១២ និងបញ្ចប់ចុងឆ្នាំ២០១៣។
- សុំ**ស្តារប្រឡាយ**១កន្លែង មានប្រវែង១៥០០ម៉ែត្រ ទទឹង៣ម៉ែត្រ ជម្រៅ២ម៉ែត្រ ពីភូមិឬស្សីយុល ដល់ព្រៃកមុខបួន និងសុំ**ស្តារអាងទឹក**១កន្លែង មានបណ្តោយ១០០ម៉ែត្រ និងទទឹង៥០ម៉ែត្រ នៅក្នុងភូមិចចិប។ សូមចាប់ពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។
- សុំ**លូ**ចំនួន១៥កង់ ដែលលូនីមួយៗមានមុខកាត់១ម៉ែត្រ សម្រាប់រំដោះទឹកលិចនៅក្នុងភូមិចារ្យ។ សូមចាប់ពីឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

**៤. ការស្នើសុំពន្លឿនការធ្វើអត្តសញ្ញាណប័ណ្ណ**

- សុំពន្លឿនការធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋដែលគ្រប់អាយុ ក្នុងឃុំស្វាយចចិបទាំងមូល។ សូមចាប់ពីដើមឆ្នាំ២០១២ និងឲ្យបានគ្រប់គ្នានៅឆ្នាំ២០១៤។

**៥. ការសាងសង់បង្គន់អនាម័យ**

- សុំសាងសង់បង្គន់អនាម័យចំនួន៣០បង្គន់ សម្រាប់ទូទាំងឃុំស្វាយចចិប។ សូមចាប់ពីឆ្នាំ២០១២ និងបញ្ចប់ដើមឆ្នាំ២០១៣។

មុនពេលបញ្ចប់សិក្ខាសាលាមានកម្មវិធីប្រគល់របាយការណ៍ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **ជ័យ ឈុំ** តំណាងគណបក្សប្រជាជនកម្ពុជា និងជាសមាជិកក្រុមប្រឹក្សាឃុំបានមានប្រសាសន៍ថា *«ខ្ញុំប្តេជ្ញាចិត្តគាំទ្រចំពោះតម្រូវការទាំងប្រាំនេះ ព្រោះវាមានភាពសមរម្យដែរ តែក៏តម្រូវឲ្យប្រជាពលរដ្ឋចូលរួមទាំងអស់គ្នាដើម្បីឲ្យសម្រេចបានតម្រូវការទាំងអស់នេះ»*។

លោក **ឃួន សុខន** តំណាងគណបក្សសមរង្ស៊ី និងជាជំទប់ទី១ បានមានប្រសាសន៍ថា «*ខ្ញុំប្តេជ្ញាចិត្តគាំទ្រតម្រូវការជាអាទិភាពទាំងប្រាំរបស់ប្រជាពលរដ្ឋដែលបានរកឃើញ និងដាក់ទៅក្នុងការអភិវឌ្ឍន៍ឃុំ និងដាក់ក្នុងកម្មវិធីនយោបាយក្នុងការបោះឆ្នោតនាពេលខាងមុខ*»។

**សិក្ខាសាលានេះមានគោលបំណងឲ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖**

១. ការយល់ដឹងអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។

២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ-សង្កាត់របស់ខ្លួន។

៣. តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ ដាច់ស្រយាលនឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដានជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរ៉ុប (EU), OXFAM NOVIB, NPA និង Forum Syd

[1]**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

១-លោក **ម្លូខ បឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៨៧១ ៣២៦**

២-អ្នកស្រី **ហេខ សុគន្ធា** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១៧ ៥៨៣ ៨៦៩**

<u>បេសកម្ម</u> ៖ បេសកកម្មរបស់ខុមហ្រ្វែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌**តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

---

[1] No. 100